# សទាសិវៈក្នុងសិល្បៈខ្មែរ

ក្នុងទេពកថា សទាសិវៈជាការធ្វើបដិហារបស់ព្រះឥសូរ មានន័យថាទ្រង់ជាទេពធំជាងគេបំផុត និងជាប្រភពនៃអ្វីៗគ្រប់យ៉ាង។ ជាពិសេសទ្រង់មានកំលាំងសក្តិក្នុងព្រះកាយដែលកំលាំងសក្តិនេះហើយ បង្កើតបានជាព្រះនាងអាទិសក្តិ (មហាទេវី)ឡើង និងមានន័យថាថាមពល ឬអំណាចដែលអាចអោយអ្វីៗមានចលនាឡើង ដើម្បីរួមគ្នាបង្កើតចក្រវាឡ។

សទាសិវៈមានឈ្មោះផ្សេងទៀតថាជាបរមេស្វរ (*Parameśvara*) នៅក្នុងគម្ពីសិវៈនិកាយ។ ជាធម្មតាការបង្ហាញរូបសទាសិវៈ គឺបង្ហាញមានព្រះភក្ត្រ៥ និងព្រះហស១០ ដែលទាក់ទងទៅនឹងទេពមួយក្នុងចំណោមរឿងសិវៈមហាស្វរមុរតិទាំង២៥រឿង។ ឧទាហរណ៍មួយចំនួនដូចជារឿង ឧមាមហេស្វរ (UmaMaheshwara) ហរិហរ (Harihara) សិវរាំ (*Siva Nataraja*) សោមាស្កន្ទ (*Somaskanda*) ឯកបទ (Ekapada) ជាដើមៗល។ ការគោរពភាគច្រើនប្រទះឃើញមាននៅឥណ្ឌាខាងត្បូង ដែលបង្ហាញជារូបមុខលឹង្គមានមុខមួយ បួន ឬប្រាំ និងបង្ហាញរូបអង្គុយព្រះភក្ត្រប្រាំ ព្រះហស១០[១] (រូបលេខ១) និងប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន ជាពិសេសចម្លាក់ខ្មែរក្នុងសតវត្សទី១០នៃគ.ស។ ដូច្នេះសទាសិវៈជួនកាលមានបង្ហាញជាមុខលឹង្គ (*Mukhalingam*) ដែលមានមុខ៤ ឬ៥។ សទាសិវៈដែលបានបង្ហាញទម្រង់បែបមុខលឹង្គនេះមាននៅប្រទេសឥណ្ឌាខាងត្បូងតាំងពីសតវត្សទី២នៃគ.សមកម្លេះ[២]។ ប៉ុន្តែសទាសិវៈដែលបានឆ្លាក់ជាចម្លាក់នៅលើផ្ទាំងថ្ម និងចម្លាក់ទោលនៅដើមសតវត្សទី១០ និង១១នៃគ.សមានសារៈសំខាន់សម្រាប់ជំនឿខ្មែរ ជាពិសេសព្រះមហាក្សត្រ។ អត្ថបទនេះនឹងបង្ហាញចម្លាក់សទាសិវៈមួយចំនួននៅសម័យអង្គរ មានជាចម្លាក់លើផ្ទាំងថ្ម និងចម្លាក់ទោល។ ត្បិតអីប្រទះឃើញមាននៅឥណ្ឌា ភាគច្រើនបង្ហាញតែក្នុងគម្ពី និងបង្ហាញជារូបចម្លាក់ខុសគ្នាខ្លះជាមួយសិល្បៈខ្មែរ។

សទាសិវៈដែលមានព្រះភក្ត្រ៥ គឺមានឈ្មោះព្រះភក្ត្រខុសៗគ្នាដូចជា៖ **ឦសន** (*Ishana*) **តត្បុរុ** (*tatpurusha*) **វាមទេវ** (*Vamadeva*) **អឃោរ** (*Aghora*) **សត្យោជត** (*Satyojata*)

[១] Sharma, 1976: 2

[២] Sharma, 1976: 3



អត្ថបទដោយ៖ លោក ជូ ជុន

ដែលគេស្គាល់ថាជាបញ្ចព្រហ្ម(Panchabrahmas)(*តារាងលេខ១*)។ ព្រះភក្ត្ររបស់សទាសិវៈបានបង្ហាញតាមទិសទាំង៤ផ្សេងៗគ្នា និង១តំណាងឋានសួគ៌(និស្កល)[៣]។ ព្រះហស្តខាងស្តាំទាំង៥កាន់ត្រីសូល៍ ពូថៅ កត្វង្គ[៤] វជ្រ អភ័យមុទ្រ និងព្រះហស្តខាងឆ្វេង៥ផ្សេងទៀតកាន់ពស់ ផ្លៃឈើ ផ្កាឈូក ស្គរ អង្កាំ និងវរទាមុទ្រ។ ជួនកាលសទាសិវៈបង្ហាញជារូបរួមគ្នាជាមួយទេពស្រី(ពរវតិ) នៅក្នុងគម្ពីសូត្ររបស់ឥណ្ឌា។ ប៉ុន្តែបញ្ចមុរតិព្រះភក្ត្រទាំង៥របស់សទាសិវៈនៅទីនេះបង្ហាញពីខ្លួន និងឈ្មោះទាំងប្រាំរបស់ព្រះសិវៈដូចជា មហេស្វរៈ រុទ្រៈ ព្រហ្ម វិស្ណុ និងសទាសិវៈផ្ទាល់[៥] ដែលទាក់ទងបញ្ចមុរិត[៦](ព្រះភក្ត្រ៥) ក្នុងទម្រង់៥ដូចជា ការបង្កើត ការថែរក្សា ការបំផ្លាញ ការជឿខុស និងការរំដោះ។ រូបរាងរបស់គាត់ផ្សេងទៀតគឺស្គាល់ថាជាមហាសទាសិវៈដែលបង្ហាញព្រះភក្ត្រ២៥ ភ្នែក៧៧ និងដៃ៥០ ដែលមានក្នុងគម្ពីវេទសិវបុរាណ[៧]។ ប៉ុន្តែនៅក្នុងសិល្បៈខ្មែរមិនមានបង្ហាញជារូបសទាសិវៈដែលមានព្រះភក្ត្រ២៥ទេ គឺមានបង្ហាញតែព្រះភក្ត្រ៥ និងព្រះភក្ត្រ១៥។

| ប្រភេទ | ឦមន *Ishana* | តត្បុរុម *Tatpurusha* | វាមទេវ *Vamadeva* | សត្យោជត *Satyojata* | អឃោរ *Aghora* |
|---|---|---|---|---|---|
| Direction looking | Upwards | East | North | West | South |
| Colour | Crystal | Gold | Red | White | Blue |
| Related *Panchabhutas* | Ether | Air | Water | Earth | Fire |
| Five acts of Almighty | liberation | delusion | Maintenance | Creation | Destruction |
| Shiva's form | Sadasiva | Maheshwara | Vishnu | Brahma | Rudra |
| Meditating point in human body | Head | Mouth | feet | genital organs | Heart |

**តារាងទី១៖** *ការបង្ហាញតាមព្រះភក្ត្រទាំង៥ និងប្រភេទខុសៗរបស់សទាសិវៈ*



**រូបលេខ១៖** *សទាសិវៈកាយវិការអង្គុយភក្ត្រ៥ព្រះហស្តនៅឥណ្ឌា*

[៣] និស្កល *(nishkala)*

[៤] កត្វង្គ *(Katvanga)*

[៥] Ramachandra Rao, 1988

[៦] បញ្ចមុរតិ *(Panchamurti)*

[៧] Sharma, 1976: 3

សម្រាប់ការបង្ហាញព្រះកត្រ្គ៩ និងព្រះហស១០ មាននៅក្នុងសិល្បៈខ្មែរពីសតវត្សទី១០និង១១ នៃគ.ស មាននៅប្រាសាទក្រហមកោះកេរ ភ្នំប្រាសាទវត្តភូ និងពើងត្បាលភ្នំគូលែន។ ប៉ុន្តែរូបសទាសិវៈមានបង្ហាញក្នុងសិល្បៈខ្មែរ មាន៤ប្រភេទទាក់ទងនឹងការបង្កើតគោត្រផលថ្មី ការឡើងគ្រងរាជ និងការរៀបចំទីក្រុងថ្មីៗរបស់ព្រះមហាក្សត្រខ្មែរ ដែលមានក្នុងគម្ពីបុរាណឥណ្ឌាផងដែរ។ សទាសិវៈមានបង្ហាញព្រះកត្រ្គ៩ ព្រះហស១០ និងអមខាងស្តាំដោយព្រះព្រហ្ម និងខាងឆ្វេងដោយព្រះវិស្ណុ។ សទាសិវៈដែលបង្ហាញក្នុងសិល្បៈខ្មែរនេះមាន៤ទម្រង់ ប៉ុន្តែក្នុងគោលបំណងតែមួយគឺបង្ហាញសម្រាប់ការបង្កើតចក្រវាឡ (លោកធាតុ) រាជធានី និងការឡើងសោយរាជរបស់ព្រះមហាក្សត្រខ្មែរ។ សិល្បៈទាំងអស់នេះបង្ហាញភាគច្រើនទាក់ ទងនឹងរចនាសម្ព័ន្ធប្រាសាទសម្រាប់រាជ និងធ្វើពីធីសាសនាសម្រាប់រាជ ដែលមានឆ្លាក់នៅលើភ្នំប្រាសាទវត្តភូ (ប្រទេសឡាវសព្វថ្ងៃ) ប្រាសាទធំកោះកេរ (ប្រាសាទក្រហម) រចនាសម្ព័ន្ធពើងត្បាល និងប្រាសាទរោងចិន (ភ្នំគូលែន) និងប្រាសាទពីរ៉ាមីតសម្រាប់រាជផ្សេងៗទៀតក្នុងតំបន់អង្គរ។ ប្រាសាទមួយចំនួនទៀតដែលគោរពតាមលំនាំប្រាសាទវត្តភូ ប្រាសាទ ចិនលើភ្នំគូលែន និងប្រាសាទធំកោះកេរ ដែលបង្ហាញជាប្រាសាទសម្រាប់រាជមានរាងជាពីរ៉ាមីត ប្រកចូលតម្កល់រូបសទាសិវៈអមដោយព្រះវិស្ណុ និងព្រះព្រហ្ម និងបន្តអមផ្លូវដោយត្រពាំង ទន្លេឬសមុទ្រ។ សម្រាប់ប្រាសាទធំកោះកេរ និងរោងចិនភ្នំគូលែនបានបង្ហាញរូបសិវលឹង្គទាំង៥បែរព្រះកត្រ្គចូលមកបារាយណ៍ដែលបែរមករកព្រះសទាសិវៈ និងប្រាសាទពីរ៉ាមីត (ត្រង់ចំណុចនេះសូមរង់ចាំអានអត្ថបទក្រោយទាក់ទងនឹងនិមិត្តរូបសំណង់ហិណ្ឌូខ្មែរ)។

សទាសិវៈមួយប្រភេទបង្ហាញជារូបឈរ មានព្រះកត្រ្គ៩ ព្រះហស១០ និងអមដោយព្រះព្រហ្មព្រះហស៤នៅខាងស្តាំ និងព្រះវិស្ណុព្រះហស៤នៅខាងឆ្វេង។ ចម្លាក់នៅលើថ្មភ្នំប្រាសាទវត្តភូបានបង្ហាញ សទាសិវៈអមដោយទេព២ទៀតអង្គុយសំពះ ក្នុងសតវត្សទី១០-១១នៃគ.ស (រូបលេខ២)។

សទាសិវៈមួយប្រភេទទៀតបង្ហាញជារូបឈរមានព្រះកត្រ្គ៩ ព្រះហស១០ កន្ទេកជន្លងនៅប្រាសាទក្រហមកោះកេរ គឺបង្ហាញស្រដៀងទៅនឹងសិវៈរាំដើមសតវត្សទី១០គ.ស ប៉ុន្តែការរៀបចំរចនាសម្ព័ន្ធរបស់ប្រាសាទទាំងអស់នេះ គឺសម្រាប់រាជ (ព្រះមហាក្សត្រ)

ដែលដូចគ្នាប្រាសាទរោងចិនភ្នំគូលែនផងដែរ (រូបលេខ២៣)។ ក្រៅពីរូបចម្លាក់ជាថ្មភក់ទោល និងលើថ្មភ្នំ ព្រះសទាសិវៈមានជារូបសំរឹទ្ធ ដែលបង្ហាញជាព្រះភក្ត្រ៥ព្រះហស១០ដែរ(រូបលេខ២៤)។ តើរូបទេពសទាសិវៈពីសំរឹទ្ធនេះប្រើសំខាន់សម្រាប់អ្វី? តើជារូបសម្រាប់ធ្វើពីធីដែលអាចប្តូរទីតាំងបានឬយ៉ាងណា? ត្រង់ចំណុចនេះយើងពុំទាន់មានភស្តុតាងច្រើនដើម្បីបកស្រាយនៅឡើយត្បិតអីការសិក្សានេះនៅមានកំណត់ និងមិនទាន់ស្វែងយល់បន្ថែមទាក់ទងនឹងពិធីសាសនាក្នុងសិលាចារឹកខ្មែរឡើយ។



**រូបលេខ២២៖** សទាសិវៈកាយវិកាឈរ មានព្រះភក្ត្រ៥ព្រះហស១០នៅភ្នំប្រាសាទវត្តភូក្នុងសតវត្សទី១១នៃគ.ស



**រូបលេខ២៣៖** សទាសិវៈកាយវិកាឈរ កន្ទែកជង្គង់មានព្រះភក្ត្រ៥ព្រះហស១០នៅប្រាសាទក្រហមសតវត្សទី១០នៃគ.ស(EFEO,FB)



**រូបលេខ២៤៖** សទាសិវៈពីសំរឹទ្ធ មានភក្ត្រ៥ព្រះហស១០ នៅសារមន្ទីរជាតិភ្នំពេញក្នុងសតវត្សទី១០នៃគ.ស

សិល្បៈចម្លាក់សទាសិវៈមួយប្រភេទទៀត បង្ហាញជារូបឈរ មានព្រះភក្ត្រ១៥ព្រះហស៣០ និងព្រះភក្ត្រ៥ ព្រះហស១០ ដែលប្រទះឃើញនៅពើងត្បាលភ្នំគូលែនក្នុងសតវត្សទី១០-១១នៃគ.ស។ (រូបលេខ២៥-៦)។ នៅក្នុងការបង្ហាញព្រះភក្ត្រ១៥ និងដៃ៣០នេះមានបង្ហាញលើទ្រឹស្តីសិវបុរាណ ដែលត្រូវការពត៌មានបន្ថែម និងសិក្សាបន្តពេលក្រោយ។ ប៉ុន្តែចម្លាក់នៅលើពើងត្បាលនេះ គឺជាប់ទាក់ទងក្នុងការរៀបចំក្រុង លទ្ធិទេវរាជ និងប្រាសាទរោងចិន ដែលមានបង្ហាញរូបទេពសទាសិវៈ។ ជាពិសេសបង្ហាញការបង្កើតលោកធាតុថ្មី ដូចជាទេពអមជុំវិញ ឬបារាយណ៍ធំមួយខាងកើត និងក្រុមប្រាសាទនៅខាងកើតបារាយណ៍បែរមុខមកប្រាសាទពីរ៉ាមីត (រូបលេខ២៧)។



**រូបលេខ២៥៖** បង្ហាញរូបសទសិរៈមាន២ប្រភេទ ក្នុងសតវត្សទី១១នៃគស



**រូបលេខ២៦៖** បង្ហាញរូបសទសិរៈមាន២ប្រភេទ ក្នុងសតវត្សទី១១នៃគស (EFEO)







**រូបលេខ២៧៖** ប្រាសាទសម្រាប់រាជ បង្ហាញរូបសទាសិរៈ រួមជាមួយរចនាសម្ព័ន្ធផ្សេងៗនៅប្រាសាទធំកោះកេរ និងពាង ចិនក្នុំគូលែន។ ដែលផ្តល់ព្រះសិវលីង្គទាំង៥បែរមុខមករកបារាយណ៍ រូបសទាសិរៈ និងប្រាសាទ(មើលតារាងទី១)



អត្ថបទដោយ៖ លោក ថូ ថុន

សិល្បៈសទាសិវៈមួយប្រភេទទៀត បង្ហាញជារូបឈរឬអង្គុយ មានព្រះភក្ត្រ៥ ព្រះហស១០ បញ្ចូលក្នុងរឿងឯកបទ (*Ekapada*) របស់រឿងមហាសូរមុរតិមួយក្នុងរឿងទាំង ២៥។ ប្រភេទចម្លាក់ទាំងអស់ខាងលើនេះដែលអ្នកស្រាវជ្រាវនិយមហៅថាត្រីមុខតិ (*Trimurti*) ដែលមានរូបទេពសំខាន់ៗ៣ ព្រះសិវៈ ព្រះវិស្ណុ និងព្រះព្រហ្ម។ ប៉ុន្តែសិល្បៈដែលបង្ហាញជាសទាសិវៈ ជាពិសេសទាក់ក្នុងរឿងទាំង២៥របស់មហាសូរមុរតិនេះ មានសារៈសំខាន់ផ្សេងៗគ្នាដូចជា សទាសិវៈតែងតែប្រើជាមួយប្រាសាទសម្រាប់រាជ សម្រាប់ពិធីសាសនា និងការបង្កើតអ្វីថ្មីដំបូងរបស់ព្រះមហាក្សត្រ។ រូបឯកបទ (*Ekapada*) បញ្ចូលជាមួយរឿងព្រះភក្ត្រសទាសិវៈនេះ នៅសារមន្ទីរជាតិភ្នំពេញ និងប្រាសាទកោះកេរជាការបង្ហាញយ៉ាងច្បាស់ទាក់ទងរឿងបង្កើតទេពទាំងពីរ ព្រះវិស្ណុ និងព្រះព្រហ្មចេញពីព្រះសទាសិវៈ[៨] (រូបលេខ៨-៩)។ រូបនេះបានបង្ហាញជាមួយទេពសទាសិវៈឈរកន្នែកជង្គង់ធំមួយនៅប្រាសាទក្រហមដែរ គឺក្នុងរឿងបង្កើតចក្រវាឡ(លោកធាតុ) ដែលតែងតែបង្ហាញជាមួយប្រាសាទសម្រាប់រាជ។



**រូបលេខ៨៖** រូបរឿងឯកបទ(*Ekapada*) និងសទាសិវៈ មកពីព្រៃជ្រូ សតវត្សទី១០-១១ NMC718 សារមន្ទីរជាតិភ្នំពេញ



**រូបលេខ៩៖** រូបរឿងឯកបទ(*Ekapada*) និងសទាសិវ ដើមសតវត្សទី១០ នៅប្រាសាទក្រហមកោះកេរ (ប្រភព៖ EFEO)

ចម្លាក់សិល្បៈព្រះសទាសិវៈមួយទៀត មានបង្ហាញជាទម្រង់មុខលឹង្គ ដែលមានឆ្លាក់ជាសាច់រឿងលើផ្តែរប្រាសាទអង្គខ្នារស្រុកកំពង់ស្វាយលើ ខេត្តកំពង់ធំ ក្នុងសម័យ

[៨] Nadine 2001: 130

មុនអង្គរសតវត្សទី៧នៃគ.ស[៩] (រូបលេខ១០)។ តើចម្លាក់សទាសិវៈឬមុខលឹង្គនេះ ជារឿងអាចឱ្យយើងយល់ពីអ្វីខ្លះ? ចម្លាក់ផ្តែរមកពីប្រាសាទវត្តអង្គខ្នារនេះ កាន់តែបន្ថែមពត៌មានកាន់តែច្បាស់ទៀតថា ជារឿងទាក់ទង់នឹងរឿងមហាស្វរមុរតិទាំង២៥។ ផ្តែរបង្ហាញពីរូបសទាសិវៈផុសចេញពីសសរភ្លើង(លិង្គោទ្ភវ) និងមានព្រះព្រហ្មនៅខាងស្តាំ ព្រះវិស្ណុនៅខាងឆ្វេង បន្ទាប់ពីការផ្ទាល់គ្នារវាង ព្រះព្រហ្មប្រែរូបជាហង្សទៅរកកំពូលសសរភ្លើង និងព្រះវិស្ណុប្រែខ្លួនជាជ្រូកព្រៃទៅរកគល់សសរភ្លើង។ បន្ទាប់មករូបសិវលឹង្គ និងសទាសិវៈព្រះកក្រុឋផុសចេញជាបន្តបន្ទាប់ ដើម្បីពន្យល់ពីការបង្កើតច្រក្រវាឡថ្មីទៅអទិទេពទាំងពីរដែលអមសង្ខាង។ ការបង្ហាញនេះខ្មែរបានយកមកអនុវត្ត និងប្រើប្រាស់សម្រាប់ធ្វើពីធីសំខាន់ៗសម្រាប់រាជ ការបូជាសាសនា និងការឡើងគ្រងរាជរបស់ព្រះមហាក្សត្រដែលប្រទះឃើញតាំងពីសតវត្សទី៧មក។ ឧទាហណ៍មួយទៀតការសង់ក្រុមប្រាសាទ(N)ជារចនាបថសំបូរព្រៃគុកក៏បានបង្ហាញពីការរៀបចំដំបូងរបស់រាជធានីដែលយករឿងនេះមកស្ថាបនានៅលើដីផ្ទាល់ និងលើប្រាសាទសម្រាប់រាជ។



***រូបលេខ១០៖*** *រូបសទាសិវៈឬមុខលឹង្គ ដែលមានបង្ហាញក្នុងរឿងមហាស្វរមុរតិទាំង២៥។ រឿងបង្ហាញពីការរៀបអភិសេកឡើងគ្រងរាជរបស់ព្រះមហាក្សត្រនៅប្រាសាទវត្តអង្គខ្នារ កំពង់ធំ សព្វថ្ងៃនៅសារមន្ទីរជាតិ*(Ka.1774) (*ប្រភព៖*John, 2012:165 )។

ដូច្នេះខ្មែរយករឿងសទាសិវៈមករៀបចំទាក់ទងនឹងប្រាសាទសម្រាប់រាជ ដូចមានបង្ហាញនៅប្រាសាទសំបូរព្រៃគុក ភ្នំគូលែន ប្រាសាទអកយំ ប្រាសាទបាគង ប្រាសាទភ្នំបាខែង ប្រាសាទធំកោះកេរ បក្សីចាំក្រុង និងបាពួនជាដើម គឺជារឿងសំខាន់តែមួយសម្រាប់ព្រះមហាក្សត្រ និងរាជ។ ប៉ុន្តែខ្មែរបានយល់ដឹង និងចេះចាំរឿងនេះតាំងពីមុន

[៩] John Guy, 2012: 165

រហូតដល់មានឆ្លាក់រូបជាសាច់រឿងនៅលើផ្តែរនេះ។ តាមចម្លាក់ផ្តែរមកពីប្រាសាទអង្គខ្នារ បានបង្ហាញពីសទាសិវៈ ឬមុខលឹង្គអមដោយព្រះព្រហ្ម និងព្រះវិស្ណុ ដូចគ្នាជាមួយការរៀបចំប្រាសាទធំកោះកេរ រោងចិនភ្នំគូលែន និងប្រាសាទសម្រាប់រាជផ្សេងដ៏ទៃទៀតដែរ។ ចម្លាក់ផ្តែរនេះបង្ហាញយ៉ាងច្បាស់ដូចគ្នាទៅនឹងប្រាសាទសម្រាប់រាជដូចជា ការរៀបចំរបស់ទេពសំខាន់ៗទាំង៣ដំបូង ការធ្វើពិធីឡើងគ្រងរាជរបស់ព្រះមហាក្សត្រតំបូង និងសង់រាជធានីថ្មីដំបូងដូចប្រាសាទលើភ្នំគូលែនរបស់ជ័យវរ្ម័នទី២ និងប្រាសាទធំកោះកេររបស់ព្រះបាទជ័យវរ្ម័នទី៤ដែរ។ រឿងសំខាន់មួយទៀតដែលទាក់ទងនឹងរឿងនេះ គឺការរៀបចំបង្កើតទេពសំខាន់ៗ ចក្រវាឡ ផែនដី ទន្លេ ស្ទឹង សមុទ្រ មនុស្ស និងសត្វជាបន្តបន្ទាប់ដែលទាក់ទងនឹងគម្ពី (*Vastu Shastra*) ឥណ្ឌា[៩០]។ ឧទាហរណ៍ដូចជាការរៀបចំប្រាសាទរោងចិនមានបារាយណ៍ធំ មានរូបទេពលើពើងត្បាល រូបសទាសិវៈ រូបវិស្ណុផ្ទំ ប្រាសាទបាល័ង្កប្រាសាទលឹង្គនៅលើភ្នំគូលែន ដែលប្រមូលទឹកចូលក្នុងបារាយណ៍ខាងកើតប្រាសាទពីរ៉ាមីតនោះ។ មួយទៀតការរៀបចំប្រាសាទធំកោះកេរ មានប្រាសាទរួម ទេពក្នុងប្រាសាទក្រហមបារាយណ៍ ប្រាសាទលឹង្គទាំង៥តំណាងឱ្យព្រះភក្ត្រទាំង៥របស់សទាសិវៈ និងបន្ទាប់មកប្រាសាទមានចម្លាក់មួយចំនួនជុំវិញត្រពាំងខ្នារ និងរហាលជាការចាប់ផ្តើមបង្កើតទេពសំខាន់ៗមួយចំនួន និងជាចុងក្រោយបង្កើតជាក្រុង មនុស្ស និងរាជវាំង។ល។

## ឯកសារយោង


**Chakrabarti Vibhuti**.
1998. "*Indian Architectural Theory: Contemporary use of Vastu Vidya*", Great Britain.

**Chevance. J-B et al.**
2019. *Mahendraparvata*: an early Angkor-period capital defined through airborne laser scanning at Phnom Kulen, journal Antiquity 93, Antiquity Publication Ltd.

**John Guy**.
2012. "Lost Kingdoms: Hindu-Buddhist Sculpture of Early Southeast Asia", New York, pp: 165.

**Nadine Dalsheimer**.
2001. "*Les collections du musee national de Phnom Penh L'art du Cambodge ancien*", Magellan, EFEO, p:130.

**Ramachandra Rao C. V.**
1988. *Siva-Mahesa (Sadasiva) Murti of Bhairavakona: an iconographical study"*.

**Sharma B.N.**
1976. "*Iconography of Sadasiva*" Abhinav Publications, pp. 1–3.


[90] Chakrabarti, 1998: 81